# របាយការណ៍
# ស្តីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៤
# និងទិសដៅការងារ ឆ្នាំ២០១៥

ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** តាមរយៈការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា ដើម្បី កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព មាតុភូមិកម្ពុជាទទួលបាននូវសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍឥតឈប់ឈរ ។

ជាមួយនេះដែរ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយមានការគាំទ្រយ៉ាងសកម្មពីស្ថាប័ន នីតិប្បញ្ញត្តិ នីតិប្រតិបត្តិ កាកបាទក្រហមកម្ពុជា វិស័យសាសនា អាជ្ញាធរមានសមត្ថកិច្ចនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទ មជ្ឈដ្ឋានជាតិ អន្តរជាតិ វិស័យឯកជន សប្បុរសជន ព្រមទាំងបណ្តាញផ្សព្វផ្សាយនានា បានអនុវត្តទិសដៅការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៤ សំដៅចូលរួមចំណែកអនុវត្ត " គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព " របស់រាជរដ្ឋាភិបាល ឈានទៅបង្ការទប់ស្កាត់ និងបង្ក្រាបបាននូវបទល្មើសគ្រឿងញៀនជាបន្តបន្ទាប់ ។ ជារួម លទ្ធផលការងារដែលអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអនុវត្តក្នុងឆ្នាំ២០១៤ នេះ មានដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀន

### ១. សភាពការណ៍គ្រឿងញៀន សកលលោក និងក្នុងតំបន់

ឆ្នាំ២០១៤នេះ សភាពការណ៍គ្រឿងញៀននៅក្នុងសកលោក និងក្នុងតំបន់ មានស្ថានភាពដូចខាងក្រោម ៖

#### *១.១ ការដាំដុះ និងការផលិតគ្រឿងញៀន*

ការដាំដុះអាភៀន និងការផលិតហេរ៉ូអ៊ីន នៅលើសកលលោកត្រូវបានកត់សំគាល់ថា ពុំទាន់មានសញ្ញាថយចុះនៅឡើយទេក្នុងឆ្នាំ២០១៤នេះ ។ ការផលិតគ្រឿងញៀនសំយោគ ATS ក៏មានការកើនឡើងនៅតាមបណ្តាប្រទេសជាច្រើននៅលើសកលលោក និងបណ្តាប្រទេសនៅតំបន់អាស៊ីផងដែរ ។

## ១.២ ការចរាចរគ្រឿងញៀនក្នុងសកលលោក និងក្នុងតំបន់

ក្រុមឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិ ដែលធ្វើសកម្មភាពខ្លាំងក្លាពាក់ព័ន្ធនឹងបណ្តាប្រទេសនៅលើសកលលោកនិងបណ្តាប្រទេសនៅអាស៊ានមាន ៤ ក្រុម គឺ :

- ក្រុមឧក្រិដ្ឋជនគ្រឿងញៀនអាហ្វ្រិកខាងលិច ( West African Drugs Syndicate)
- ក្រុមឧក្រិដ្ឋជនគ្រឿងញៀនម៉ិកស៊ិចកូ (Mixican-Sinaloa Drugs Syndicate)
- ក្រុមឧក្រិដ្ឋជនគ្រឿងញៀនចិន (Chinese Drugs Syndicate)
- ក្រុមឧក្រិដ្ឋជនគ្រឿងញៀនអៀរ៉ង់ (Iranian Drugs Syndicate)

**ផ្លូវចរាចរគ្រឿងញៀនជាទូទៅ** ដែលក្រុមឧក្រិដ្ឋជនតែងប្រើប្រាស់ មានដូចខាងក្រោម ៖

- គ្រឿងញៀនប្រភេទ ហេរ៉ូអ៊ីន និង ជ័រអាភៀន ដែលនាំពីតំបន់អឌ្ឍចន្ទមាស ត្រូវបាននាំឆ្លងកាត់ប្រទេសឥណ្ឌា ណេប៉ាល់ បង់ក្លាដេស ចូលមកប្រទេសមីយ៉ាន់ម៉ា រួចចែកចាយបន្តទៅកាន់បណ្តាប្រទេសនានានៅក្នុងតំបន់
- តំបន់អាមេរិកខាងត្បូង (Brazil Peru Agentina) និង តំបន់អាហ្វ្រិក (Nigeria Ghana South-Africa) ជាតំបន់នាំចេញគ្រឿងញៀនប្រភេទ កូកាអ៊ីន មេតំហ្វេតាមីនក្រាមម្សៅ (ICE) និង ហេរ៉ូអ៊ីន
- មជ្ឈិមបូព៌ា (Middle East) ជាគោលដៅផ្ទេរគ្រឿងញៀនពីមធ្យោបាយដឹកជញ្ជូនមួយ ទៅមធ្យោបាយដឹកជញ្ជូនមួយទៀត នៅលើផ្ទៃសមុទ្រ
- បណ្តាដែនសមុទ្រនៃប្រទេសមួយចំនួននៅអាស៊ាន ជាកន្លែងសំចត និងផ្ទេរគ្រឿងញៀន ដើម្បីនាំទៅកាន់បណ្តាប្រទេសមួយចំនួននៅអាស៊ី ព្រមទាំងមានការដឹកគ្រឿងញៀនឆ្លងកាត់បណ្តាប្រទេសនៅអាស៊ី-អាគ្នេយ៍មួយចំនួនផ្សេងទៀត មុននឹងទៅដល់ប្រទេសជាគោលដៅពិតប្រាកដ ។

**ដោយឡែក ផ្លូវចរាចរ មេតំហ្វេតាមីន** WY និង **មេតំហ្វេតាមីនក្រាមម្សៅ** (ICE) ពីតំបន់ត្រីកោណមាស មានដូចតទៅ ៖

- ពីតំបន់ត្រីកោណមាស ចូលទៅប្រទេសឥណ្ឌា, បង់ក្លាដេស, ថៃ, វៀតណាម និង ប្រទេសចិន
- ពីតំបន់ត្រីកោណមាស ទៅប្រទេសឡាវ ចូលមកកម្ពុជា ហើយចេញទៅប្រទេសវៀតណាម និងប្រទេសថៃ

**ជាការកត់សំគាល់គឺ** ក្រុមឧក្រិដ្ឋជនអាហ្វ្រិកខាងលិច ដែលមានសមាសភាពចម្រុះជាតិសាសន៍ នៅតែជាក្រុមឧក្រិដ្ឋជនគ្រឿងញៀនដែលធ្វើសកម្មភាពយ៉ាងសកម្មក្នុងការដឹកជញ្ជូនគ្រឿងញៀនប្រភេទ កូកាអ៊ីន ជ័រអាភៀន ហេរ៉ូអ៊ីន មេតំហ្វេតាមីន (គ្រាប់-ក្រាមម្សៅ) ប្រេងនិងជ័រកញ្ឆា ដោយបាននាំពីតំបន់ផលិត ឆ្លងកាត់ប្រទេសមួយចំនួនក្នុងតំបន់មុននឹងទៅដល់ប្រទេសគោលដៅដែលជាទីផ្សារប្រើប្រាស់ ។ ល្បិចកលក្នុងការចរាចរគ្រឿងញៀនភាគច្រើនធ្វើឡើងតាមរយៈការរុំព័ទ្ធជាប់ដងខ្លួន, ការលាក់ក្នុងសម្ភារជាប់ខ្លួន, ការក្លែងគ្រឿងញៀនជាសម្ភារផ្សេងៗ, ការលាក់គ្រឿងញៀនក្នុងសក់ក្រងបែបអាហ្វ្រិក, ការដាក់បន្លំជាមួយរទេះរុញមនុស្សចាស់ជរា, បាតវ៉ាលី ឬការលាក់ក្នុងកញ្ចប់បញ្ញើ ដូចជា កញ្ចប់បញ្ញើប្រៃសណីយ៍ ជាដើម ។

ជារួម បណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ (កម្ពុជា ថៃ ឡាវ វៀតណាម មីយ៉ាន់ម៉ា ចិន) នៅតែបន្តកត់សំគាល់ទៅលើតំបន់ ត្រីកោណមាស និង អឌ្ឍចន្ទមាស ថាជាប្រភពដ៏សំខាន់នៃការផលិតគ្រឿងញៀន ព្រមទាំងកត់សំគាល់ផងដែរនូវការចរាចរគ្រឿងញៀន តាមផ្លូវអាកាសពីតំបន់ផ្សេងៗ ពិសេសពីបណ្តាប្រទេសមួយចំនួននៅអាមេរិកខាង

ត្បូង ប្រទេសនីហ្សេរីយ៉ា និងប្រទេសអៀរ៉ង់ ចូលនិងឆ្លងកាត់បណ្តាប្រទេសនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ។

### ១.៣ ការប្រើបំពានគ្រឿងញៀន

ការប្រើបំពានគ្រឿងញៀនប្រភេទ ATS នៅតែមានសញ្ញាកើនឡើងគួរឱ្យកត់សំគាល់នៅឡើយ ទាំងនៅបណ្តាប្រទេសអាស៊ាន ក៏ដូចជានៅលើសកលលោក ។ ស្របពេលជាមួយគ្នានេះ ការប្រើបំពានសារជាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ (New Psychoactive Substances) ក៏មានសញ្ញាកើនឡើងយ៉ាងឆាប់រហ័ស ដែលសារជាតុនេះ មិនមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីសារជាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ឆ្នាំ១៩៧១ ។ សារជាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទនេះ អាចបណ្តាលឱ្យញៀននិងមានគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ដូចសារជាតុញៀនដែលកំពុងត្រួតពិនិត្យដែរ ។

## ២. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

### ២.១. ការកែច្នៃផលិត ការដាំដុះ និងការចម្រាញ់ប្រេងរុក្ខជាតិ

ឆ្នាំ២០១៤នេះ ទោះបីជាមានការរឹបអូសបាននូវសារជាតុគីមីផ្សំ គូលុយអែន តាមទិសខេត្តតាកែវ និងសារជាតុគីមីចម្រុះ នៅស្រុកស្អាង ជិត ៣០ តោន ក៏ពិតមែន ប៉ុន្តែទាក់ទងទៅនឹងការលបលួចកែច្នៃផលិតគ្រឿងញៀនសំយោគ ATS មិនឃើញមានសញ្ញាកើតឡើងទេ ។

ដោយឡែក ដំណាំកញ្ឆា ត្រូវបានកត់សំគាល់ឃើញមានសកម្មភាពលួចដាំដុះតិចតួចនៅខេត្តមួយចំនួន ដូចជានៅ ខេត្តបាត់ដំបង ពោធិ៍សាត់ និង ខេត្តកំពត ប៉ុន្តែត្រូវបានអាជ្ញាធរដែនដីចុះទៅបំផ្លាញចោលដល់ទីកន្លែងដាំដុះ ។ ជាមួយនេះ ការលបលួចចម្រាញ់យកប្រេងម្រះព្រៅភ្នំ ក៏ពុំឃើញមានសកម្មភាពថ្មីកើតឡើងដែរ ប៉ុន្តែសមត្ថកិច្ចខេត្តពោធិ៍សាត់បានរកឃើញប្រេងម្រះព្រៅភ្នំ ដែលក្រុមឈ្មួញបានកប់លាក់ទុកក្នុងដីចំនួន ១៣៩ ប៊ីដុង ស្មើនឹង ៥.២២០ គ.ក្រ ។ វាគឺជាប្រេងម្រះព្រៅភ្នំ ដែលនៅសល់ក្រោយពីការលបលួចចម្រាញ់តាំងពីយូរមកហើយ ។

### ២.២. ការចរាចរគ្រឿងញៀន

ការចរាចរគ្រឿងញៀនត្រូវបានកត់សំគាល់ទាំងនៅតាម ផ្លូវគោក ផ្លូវអាកាស ផ្លូវសមុទ្រ ៖

- **តាមផ្លូវគោក** សំខាន់គឺច្រកនៃបណ្តាខេត្តស្ថិតនៅភាគឦសានប្រទេស ជាពិសេសគឺច្រកនៃខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ ។ ប្រភេទគ្រឿងញៀនដែលនាំចូលមកតាមច្រកនេះ ភាគច្រើនជាគ្រឿងញៀនសំយោគ ATS (WY-ICE) និង ហេរ៉ូអ៊ីន ។ ដោយឡែកនៅទិសនិរតី ក៏មានការលួចនាំចូលដោយខុសច្បាប់នូវសារជាតុគីមីផ្សំ តាមច្រកនៃខេត្តតាកែវ ។
- **តាមផ្លូវអាកាស** សំខាន់គឺច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅតែបន្តមានការនាំឆ្លងកាត់នូវគ្រឿងញៀនប្រភេទកូកាអ៊ីន ។
- **តាមផ្លូវសមុទ្រ** កងទ័ពជើងទឹកស្នាក់ការលំហសមុទ្រឡាំដាំ នៃទិសខេត្តកោះកុង បានរកឃើញនិងបង្ក្រាបបាន១ករណី មេតំហ្វេតាមីនគ្រាប់ WY ។

**ជាមួយនេះ** យើងក៏បានរកឃើញការលាក់បង្កប់សារជាតុគមីផ្សំ អេហ្វេឌ្រីន ចំនួន ២ លើក មានបរិមាណជិត ២៦ គីឡូក្រាម ដែលលាក់នៅក្នុងកញ្ចប់បញ្ញើប្រៃសណីយ៍ បម្រុងផ្ញើចេញទៅក្រៅប្រទេសផងដែរ ។

### ២.៣. ការប្រើប្រាស់គ្រឿងញៀន

អ្នករងគ្រោះដោយសារគ្រឿងញៀន ដែលបានចូលទៅទទួលយកសេវាព្យាបាលនៅក្នុងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ និង ឯកជន នៅក្នុងឆ្នាំ២០១៤នេះ មាន ៣.២៤៩ នាក់ ។ ក្នុងចំនួននេះ យើងបានរកឃើញអ្នកប្រើដែលមានអាយុចន្លោះពី ១៨ ទៅ ៣៥ឆ្នាំ មានប្រមាណ ៩០ % និង អ្នកប្រើគ្រឿងញៀនប្រភេទមេតំហ្វេតាមីន ICE មានប្រមាណ ៨២ % និង WY មានប្រមាណ ១០ % ។

ជាមួយនេះ នៅដើមឆ្នាំ២០១៤ បានលេចឡើងនូវសកម្មភាពនៃការនាំចូលនិងការធ្វើអាជីវកម្មផលិតផលស៊ីហ្សា (SISHA) និងបារីអេឡិចត្រូនិច (E-Cigarette) បានរីករាលដាលនៅតាមរាជធានី-ខេត្តគោលដៅមួយចំនួន ។ ផលិតផលនេះ មានផ្ទុកសារជាតុនីកូទីនសំយោគក្នុងកម្រិតខ្ពស់ ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពធ្ងន់ធ្ងរជាងបារី ។ ឧបករណ៍ ឥរិយាបថ និងរបៀបប្រើប្រាស់ផលិតផលនេះ មានលទ្ធភាពងាយជំរុញនិងលើកទឹកចិត្តឈានទៅរកការប្រើប្រាស់ប្រភេទ គ្រឿងញៀនខុសច្បាប់ផ្សេងៗទៀត ប៉ុន្តែបន្ទាប់ពីបានទទួលបទបញ្ជាពីរាជរដ្ឋាភិបាល បញ្ហានេះត្រូវបានទប់ស្កាត់និងបង្ក្រាបទាន់ពេលវេលា ។

## II. ការដឹកនាំ

### ១. ការដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ

ថ្នាក់ដឹកនាំនៃស្ថាប័នកំពូលរបស់ជាតិដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាប្រមុខ បានបន្តការយកចិត្តទុកដាក់ណែនាំនូវគោលការណ៍សំខាន់ៗ និងចូលរួមផ្ទាល់ក្នុងសកម្មភាពការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន មានជាអាទិ៍ :

- ចង្អុលដឹកនាំបញ្ជា ឱ្យអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចាត់វិធានការជាបន្ទាន់ និងម៉ឺងម៉ាត់បំផុត ដើម្បីទប់ស្កាត់ចំពោះការប្រើប្រាស់ និងការនាំចូលស៊ីហ្សា និងបារីអេឡិចត្រូនិច នៅក្នុងព្រះរាជាណាចក្រកម្ពុជា (ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤)
- ផ្តល់អនុសាសន៍ ៦ ចំណុច ដល់ក្រសួងទេសចរណ៍ពាក់ព័ន្ធនឹងសកម្មភាពបង្ការ ទប់ស្កាត់ និងការធ្វើអាជីវកម្មផលិតផលស៊ីហ្សា (SHISA) និង បារីអេឡិចត្រូនិច (E-Cigarette) ក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារទេសចរណ៍ ២០១៣-២០១៤ និងទិសដៅអនុវត្តបន្ត "ទេសចរណ៍កម្ពុជាឆ្ពោះទៅសមាហរណកម្មអាស៊ានឆ្នាំ២០១៥" និងអបអរសាទរទិវាជាតិទីក្រុងស្អាតឆ្នាំ២០១៤ (ធ្វើនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤)
- ចេញអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ (មាត្រា១២ ចំណុច.ច បាននិយាយពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន)
- ផ្ញើសារលិខិតគាំទ្រនិងអំពាវនាវដល់ក្រសួងស្ថាប័ន អាជ្ញាធរដែនដី សហគមន៍ និងពលរដ្ឋគ្រប់រូបនៅក្នុងឱកាសខួបលើកទី៦៤ ទិវាកុមារអន្តរជាតិ ១មិថុនា, ខួបលើកទី១២ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា ទិវាកុមារកម្ពុជាឆ្នាំ២០១៤
- ចូលរួមប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤
- ផ្ញើសារលិខិតអំពាវនាវដល់សិស្សានុសិស្ស និស្សិត យុវជន យុវនារី ក្នុងឱកាសបើកបវេសនកាលឆ្នាំសិក្សា ២០១៤-២០១៥ (ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤) ឱ្យមានការប្រុងប្រយ័ត្នពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

## ២. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

អនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាល ក៏ដូចជាទិសដៅការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៤ ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តណែនាំ និងដឹកនាំក្រសួងជាសមាជិកនូវកិច្ចការសំខាន់ៗក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាអាទិ៍ ៖

១. ការងារអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ និងបដិសេធគ្រឿងញៀន : បង្កើនការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ និងតាមសហគមន៍ឱ្យកាន់តែសកម្មថែមទៀត តាមគ្រប់រូបភាព គ្រប់ពេលវេលា និងគ្រប់ទីកន្លែង ។ ជាមួយនេះ ត្រូវធ្វើបច្ចុប្បន្នភាពលើខ្លឹមសារឯកសារសម្រាប់ការអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ព្រមទាំង រៀបចំកម្មវិធីប្រឡងតែងកំណាព្យ និងប្រឡងគូរគំនូរប្រឆាំងគ្រឿងញៀន នៅតាមបណ្តាខេត្តគោលដៅ និងជំរុញការរៀបចំសាលារៀនបៃតង (សាលារៀនគ្មានគ្រឿងញៀន) ។

២. ការងារកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាលនិងស្តារនីតិសម្បទា : រៀបចំវគ្គបណ្តុះបណ្តាលបំប៉ន ស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍នៅតាមមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងធ្វើការផ្សព្វផ្សាយឱ្យបានជ្រួតជ្រាបដល់ប្រជាពលរដ្ឋទូទៅ ព្រមទាំងពិភាក្សាជាមួយតំណាងអយ្យការ តុលាការ ពាក់ព័ន្ធនឹងការចោទប្រកាន់អ្នកប្រើប្រាស់គ្រឿងញៀន ឱ្យទៅទទួលយកសេវាព្យាបាលនៅតាមកន្លែងខាងលើ ។ ជា មួយនេះ ត្រូវធ្វើការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប និងព្យាបាលអ្នកញៀនគ្រឿងញៀនឱ្យបានសមស្រប និងត្រូវជំរុញការរៀបចំសេវាព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមប៉ុស្តិ៍សុខភាពពន្ធនាគារ ។ ទន្ទឹមនេះ ត្រូវរៀបចំឯកសារគោលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ និងអាជ្ញាធរ មូលដ្ឋាន ក្នុងការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ និងគោលនយោបាយ / គោលការណ៍ណែនាំ ស្តីពីការ អនុវត្តកម្មវិធីម្ជុល/ស៊ីរ៉ាំងនៅកម្ពុជា ព្រមទាំងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងស៊ីជម្រៅ ដើម្បីលើកកម្ពស់ការយល់ដឹងពីការអនុវត្តកម្មវិធីម្ជុល/ស៊ីរ៉ាំងនេះ ។

ជាមួយនេះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ បានដឹកនាំកិច្ចប្រជុំគណៈកម្មការអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ដើម្បីជំរុញដល់អនុគណៈកម្មការអប់រំផ្សព្វផ្សាយ, អនុគណៈកម្មការព្យាបាល ស្តារនីតិសម្បទា និងអនុគណៈកម្មការអនុវត្តន៍ច្បាប់ ឱ្យបង្កើនសកម្មភាពការងាររបស់ខ្លួន ជាពិសេស ជំរុញលើការងារព្យាបាលដោយផ្អែកលើសហគមន៍នៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ដែលបានរៀបចំរួច ។

៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ : បន្តបើកវគ្គបណ្តុះបណ្តាលសមត្ថភាពជំនាញដល់កងយោធពលខេមរភូមិន្ទ តាមបណ្តាភូមិភាគ វរការពារព្រំដែន និងមន្ត្រីអនុវត្តន៍ច្បាប់នៅថ្នាក់ក្រោមជាតិ ។ ជាមួយនេះ ត្រូវសហការជាមួយក្រសួងយុត្តិធម៌ ដើម្បីធ្វើសម្រង់ចំនួនសំណុំរឿងបទល្មើសគ្រឿងញៀន និង សហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីធ្វើសម្រង់ចំនួនបទល្មើសនានា ក្នុងឆ្នាំ២០១៤ ដែលកើតឡើងហើយពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀន និងចំនួនបទល្មើសគ្រឿងញៀនដែលពាក់ព័ន្ធជាមួយ មន្ត្រីរាជការ សមត្ថកិច្ចនគរបាល យោធា ព្រមទាំងស្នើទៅក្រសួងមហាផ្ទៃ ដើម្បីពិនិត្យលទ្ធភាពក្នុងការបំពេញបន្ថែមក្របខណ្ឌនគរបាលនៅថ្នាក់ប៉ុស្តិ៍រដ្ឋបាល ក្នុងរាជធានីភ្នំពេញ ។

៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ : រៀបចំបែបបទប្រគល់ សារធាតុគីមីផ្សំ ប្រេងម្រះព្រៅភ្នំ ដែលចាប់យក ជូនទៅសមត្ថកិច្ចពាក់ព័ន្ធនានា ដើម្បីចាត់ចែងនិងគ្រប់គ្រងបន្ត ។ ទន្ទឹមនេះ ត្រូវរៀបចំរបាយការណ៍បូកសរុបពាក់ព័ន្ធនឹងការចរាចរ ការចាប់យកប្រេងម្រះព្រៅភ្នំ និងវិធានការដោះស្រាយកន្លងមក ដើម្បីរាយការណ៍ស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាល ។ ក្រៅពីនោះ ត្រូវរៀបចំឯកសារសម្រាប់បណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការស៊ើបអង្កេតការចរាចរសារធាតុគីមីផ្សំ និងមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់ ព្រមទាំងសិក្សាស្រាវជ្រាវប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទដើម្បីដាក់បញ្ចូលទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន : ជំរុញខេត្តជាប់ព្រំដែនឱ្យរៀបចំ និងចូលរួមកិច្ចប្រជុំឱ្យបានទៀងទាត់ រវាងថ្នាក់ខេត្តនិងខេត្ត ស្រុកនិងស្រុកជាប់ព្រំដែននៃប្រទេសថៃ ឡាវ និងវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដោយមានការចូលរួមពីផ្នែកកងទ័ព ។ ពង្រឹងយន្តការនៃកិច្ចសហប្រតិបត្តិការទ្វេភាគី របស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ព្រមទាំងរៀបចំកសាងភូមិ ឃុំ និងសហគមន៍គ្មានគ្រឿងញៀននៅតាមបណ្តាក្រុង ស្រុកតាមព្រំដែន ។

៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា : ខិតខំពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការតាមរយៈយន្តការទ្វេភាគី ត្រីភាគី ពហុភាគី និងតាមគ្រប់រូបភាព ដើម្បីចូលរួមចំណែកដោះស្រាយបញ្ហាគ្រឿងញៀន ។

៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ : យកចិត្តទុកដាក់ពង្រឹងស្ថាប័នសេនាធិការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តយុទ្ធសាស្ត្រពហុវិស័យ ព្រមទាំងជំរុញការរៀបចំបណ្តាលិខិតបទដ្ឋានគតិយុត្តិ ដែលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនបានបញ្ញត្តិ ។ ជាមួយគ្នានេះ ត្រូវរៀបចំផ្សព្វផ្សាយ ជាអាទិ៍ អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់មន្ត្រីរាជការនៅតាមក្រសួង ស្ថាប័ន ជាសមាជិករបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង មេឃុំ ចៅសង្កាត់ នគរបាលប៉ុស្តិ៍រដ្ឋបាល មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទ វិស័យឯកជន និង អង្គការដៃគូពាក់ព័ន្ធនានា នៅតាមរាជធានី ខេត្ត ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានក្រសួង ស្ថាប័នជាសមាជិក, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ជាខ្សែបណ្តោយ, អង្គការមិនមែនរដ្ឋាភិបាលជាដៃគូ បានបង្កើនការយកចិត្តទុកដាក់អនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀន តាមរយៈសកម្មភាពបួនជាសំខាន់គឺ ការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយប្រចាំថ្ងៃសប្តាហ៍, ការអប់រំតាមសហគមន៍, ការបណ្តុះបណ្តាលក្រុមជនបង្គោល, ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិ-ភាពរបស់រាជរដ្ឋាភិបាល ដែលមានមហាជនចូលរួមសរុបចំនួន **៨.៥៩១.៨០៧** នាក់ លើ ៦.៤៥៤.៤៤៦ នាក់ នៃឆ្នាំ ២០១៣ កើនឡើង ៣៣,១១ % ។

**ក្នុងនោះ** សកម្មភាពការងារដែលបានអនុវត្តដោយ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ រួមមាន ៖

- **ផ្តល់កិច្ចសម្ភាសន៍តាមប្រព័ន្ធផ្សព្វផ្សាយ** ចំនួន ៦ លើក ក្រោមប្រធានបទស្តីពី យុទ្ធសាស្ត្រជាតិក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន, លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនឆ្នាំ២០១៣, អត្តសញ្ញាណនិងឥទ្ធិពលនៃគ្រឿងញៀន, ការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន, អត្ថន័យនៃការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, កម្មវិធី យុវជនថ្ងៃនេះ ក្រោមប្រធានបទ ការចូលរួមរបស់យុវជនដើម្បីទប់ស្កាត់ និងបង្ការការប្រើប្រាស់គ្រឿងញៀន (កម្មវិធីរបស់អគ្គនាយកដ្ឋានវិទ្យុ ទូរទស្សន៍បាយ័ន) ។
- **ការអប់រំផ្សព្វផ្សាយនៅតាមសហគមន៍** ចំពោះមុខសញ្ញាងាយប្រឈមនឹងគ្រោះថ្នាក់ និងគោលដៅងាយកើតឡើងនូវបទល្មើសគ្រឿងញៀន រួមទាំងការបណ្តុះបណ្តាលជនបង្គោល រួមមាន ៖
  - កិច្ចសហការជាមួយក្រសួង-ស្ថាប័ន, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត, ស្ថានីយវិទ្យុ ទូរទស្សន៍របស់រដ្ឋ និងឯកជន, បណ្តាក្រុមហ៊ុនឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ទៅក្នុងកម្មវិធីប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្ម តាមរាជធានី ខេត្តគោលដៅ, កម្មវិធីប្រឡងគូរគំនូរប្រឆាំងគ្រឿងញៀន, ពិធីបុណ្យសមុទ្រ ។
  - ការចូលរួមធ្វើបទឧទ្ទេសនាម ក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលានានា អំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនដល់កងកម្លាំងប្រដាប់អាវុធ, មន្ត្រីរាជការ លោកគ្រូ-អ្នកគ្រូ សិស្ស និស្សិត នៃសាកលវិទ្យាល័យ វិទ្យាល័យ អនុវិទ្យាល័យ, ការរៀបចំវគ្គបណ្តុះបណ្តាលបញ្ជ្រាបវិធានការ និងហានិភ័យក្នុងការសេពគ្រឿងញៀនដល់ក្រុមពិធីករ សិល្បករ និងតារាកំប្លែង ឱ្យមានការយល់ដឹងនិងចូលរួមអប់រំផ្សព្វផ្សាយបន្ត ។
  - ការចូលរួមបញ្ជ្រាបខ្លឹមសារអប់រំពីគ្រឿងញៀន តាមរយៈការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល និងកម្មវិធីគម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាលជាដៃគូ ។

ជាមួយនេះ តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) មានប្រិយមិត្តចូលអានចំនួន ***៣៧៦.៦៨១*** ដង ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសហការនិងចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេស ទាំងក្នុងកម្រិតទ្វេភាគី ពហុភាគីនៅក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ សរុបបានចំនួន ៤៨ លើក ជាមួយក្រសួង-ស្ថាប័ន និងអង្គការជាដៃគូពាក់ព័ន្ធ ដើម្បីពិភាក្សា ពិគ្រោះយោបល់ និងរៀបចំលិខិតបទដ្ឋានគតិយុត្តិនានា សំដៅអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាព ដែលមានមន្ត្រីចូលរួមសរុប **២.១២៣** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ **២៣** រូប មន្ត្រីពាក់ព័ន្ធ **២.១០០** នាក់) ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៣ ។

## ២.២. ការព្យាបាលដោយផ្អែកលើសហគមន៍

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់ក្នុងការរៀបចំ និងចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ទាំងក្នុងនិងក្រៅប្រទេស ជាលក្ខណៈទ្វេភាគី ពហុភាគីនៅក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ ជាមួយក្រសួង-ស្ថាប័ន និងអង្គការជាដៃគូពាក់ព័ន្ធនឹងការងារព្យាបាល សរុបចំនួន **២៥** លើក មានអ្នកចូលរួមចំនួន **១.០១៥** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ **១៨** នាក់) ។

ក្នុងនោះ ការងារជាគោលសំខាន់ៗរួមមាន សិក្ខាសាលាបូកសរុបនិងពិនិត្យលើលទ្ធផលការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ, ការវាយតម្លៃសេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប, ការចុះពិនិត្យស្ថានភាពរស់នៅ និងការព្យាបាល/ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ, កិច្ចប្រជុំរៀបចំកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន, កិច្ចប្រជុំថ្នាក់សង្កាត់ស្តីពីការអនុវត្តការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍នៅរាជធានីភ្នំពេញ (ប្រជុំបាន ២១ សង្កាត់ មានអ្នកពាក់ព័ន្ធចូលរួម ៦៣០ នាក់) ។

**សេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀន ក្នុងឆ្នាំ២០១៤** បានពង្រីកនៅទូទាំងប្រទេសចំនួន ២៤០ កន្លែង (៦០ មន្ទីរពេទ្យថ្នាក់ជាតិ-មន្ទីរពេទ្យបង្អែក) និង (១៨០ មណ្ឌលសុខភាព) ។ ក្នុងចំនួននេះ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពដែលកំពុង**ផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍** មាន ៤៩ កន្លែង (មន្ទីរពេទ្យបង្អែក ១២ កន្លែង និង មណ្ឌលសុខភាព ៣៧ កន្លែង) ដែលមានទីតាំងនៅ ៖

- រាជធានីភ្នំពេញ មន្ទីរពេទ្យបង្អែក ៧ កន្លែង មណ្ឌលសុខភាព ១៤ កន្លែង
- ខេត្តបាត់ដំបង មន្ទីរពេទ្យបង្អែក គ្មាន មណ្ឌលសុខភាព ៣ កន្លែង
- ខេត្តបន្ទាយមានជ័យ មន្ទីរពេទ្យបង្អែក ៥ កន្លែង មណ្ឌលសុខភាព ២០ កន្លែង

(ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៣)

**ចំពោះអ្នកញៀនគ្រឿងញៀនដែលបានទទួលសេវាព្យាបាលក្នុងឆ្នាំ ២០១៤** សរុបមាន ២.៣៥៥ នាក់ ក្នុងនោះ ៖

- រាជធានីភ្នំពេញ មាន ៣០៤ នាក់ (ហេរ៉ូអ៊ីន ២៨២ នាក់)
- ខេត្តបន្ទាយមានជ័យ មាន ១៩៩៧ នាក់
- ខេត្តបាត់ដំបង មាន ៥៤ នាក់

## ២.៣. ការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ

មណ្ឌលបណ្តោះអាសន្នរបស់រដ្ឋទាំង៧កន្លែង បានទទួលអ្នកស្ម័គ្រចិត្តចូលមកបន្សាប ព្យាបាលភាពញៀនសារធាតុញៀនសរុប ***២.៨៧៥*** នាក់ ក្នុងនោះ ៖

- ✓ បានធ្វើសមាហរណកម្ម ទៅកាន់គ្រួសារ និងសហគមន៍វិញ ***១.៧៩៥*** នាក់
- ✓ បោះបង់ការព្យាបាល ***៦០*** នាក់
- ✓ កំពុងស្នាក់នៅព្យាបាលបន្ត ***១.០២០*** នាក់

ក្រៅពីការងារព្យាបាល មណ្ឌលបណ្តោះអាសន្នរបស់រដ្ឋទាំង៧កន្លែង បានធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈដល់អ្នករងគ្រោះដោយសារគ្រឿងញៀនពីជំនាញ កាត់ដេរ សម្អាងការ កុំព្យូទ័រ ជួសជុលម៉ូតូ ចម្លាក់កៅអីថ្ម ជាដើម ។

### ២.៤. ការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅតាមមណ្ឌលបណ្តោះអាសន្នរបស់ឯកជន

មណ្ឌលបណ្តោះអាសន្នរបស់ឯកជន ទាំង ៣ កន្លែង បានទទួលអ្នកស្ម័គ្រចិត្តចូលមកបន្សាប ព្យាបាលភាពញៀនសារធាតុញៀន សរុប ***៣៧៤*** នាក់ ក្នុងនោះ ៖

- ✓ បានធ្វើសមាហរណកម្ម ទៅកាន់គ្រួសារ និងសហគមន៍វិញ ***១០៨*** នាក់
- ✓ បោះបង់ការព្យាបាល (គ្មាន)
- ✓ កំពុងស្នាក់នៅព្យាបាលបន្ត ***២៦៦*** នាក់

**សរុបរួម** អ្នកចូលមកបន្សាប ព្យាបាល សារធាតុញៀន មានចំនួន ***៣.២៤៩*** នាក់ ក្នុងនោះ :

- ✓ បានធ្វើសមាហរណកម្មទៅកាន់គ្រួសារ និងសហគមន៍ ***១.៩០៣*** នាក់
- ✓ បោះបង់ការព្យាបាល ***៦០*** នាក់
- ✓ កំពុងស្នាក់នៅព្យាបាលបន្ត ***១.២៨៦*** នាក់

(ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៣)

ក្នុងចំនួនជនរងគ្រោះ ទាំង ១.២៨៦ នាក់ ដែលកំពុងស្នាក់នៅព្យាបាលបន្ត យើងបានរកឃើញ :

**អាយុអ្នកប្រើគ្រឿងញៀន**

| ចំនួនអ្នកប្រើ | ៩ឆ្នាំចុះ | ១០-១៧ ឆ្នាំ | ១៨-២៥ ឆ្នាំ | ២៦-៣៥ ឆ្នាំ | ៣៦-៤៥ ឆ្នាំ | ៤៦ ឆ្នាំឡើង |
|---|---|---|---|---|---|---|
| ១.២៨៦ | គ្មាន | ២,៩៥ % | ៦២ % | ២៩ % | ៦ % | ១ % |

**ប្រភេទគ្រឿងញៀនប្រើប្រាស់**

| ចំនួនអ្នកញៀន | WY | ICE | អ៊ិចស្តាស៊ី | ហេរ៉ូអ៊ីន | កេតាមីន | កញ្ឆា | ការហិត | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| ១.២៨៦ | ១០,១០ % | ៨៤,២១ % | ០,៣៨ % | ១,២៤ % | ០,៦៩ % | ០,៧៧ % | ២,០២ % | ២,៤៨ % |

**មុខរបរអ្នកប្រើប្រាស់គ្រឿងញៀន**

| ចំនួនអ្នកញៀន | មន្ត្រីរាជការ | សិស្ស និស្សិត | អ្នកនៅកន្លែងសប្បាយ | កម្មករ ពលករ | អ្នកជំនួញ | គ្មានមុខរបរពិតប្រាកដ | ជនអនាថា | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| ១.២៨៦ | ១,៩៤ % | ១៩,០៥ % | | ១៦,០១ % | ៥,៦៧ % | ៥៤,១២ % | ១,៣២ % | ៣,៨១ % |

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

បានបន្តយកចិត្តទុកដាក់ក្នុងការពង្រឹងប្រសិទ្ធភាពការងារស្ថាប័នអនុវត្តន៍ច្បាប់ តាមរយៈការរៀបចំនូវ កិច្ចប្រជុំ / សិក្ខាសាលា / វគ្គបណ្តុះបណ្តាល ទាំងនៅក្នុងនិងក្រៅប្រទេស បានចំនួន ៥៣ លើក មានអាជ្ញាធរមានសមត្ថកិច្ចនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ កងកម្លាំងប្រដាប់អាវុធ មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទ និងបុគ្គលិកទទួលខុសត្រូវតាមច្រកអាកាសយានដ្ឋានអន្តរជាតិ ចូលរួមចំនួន ***១០.៣៨៤*** នាក់ (ក្នុងប្រទេស ១០.១៧៩ នាក់ មន្ត្រីអគ្គលេខាធិការដ្ឋាន ៨២ នាក់), (ក្រៅប្រទេស ២០៥ នាក់ មន្ត្រីរបស់លេខាធិការដ្ឋាន ៣៩ នាក់) ដូចមានក្នុងឧបសម្ព័ន្ធទី៤ ។

បណ្តាកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលជំនាញជាគោលសំខាន់ៗ រួមមាន ការពង្រឹងសមត្ថភាពការប្រមូល

ទិន្នន័យព័ត៌មានគ្រឿងញៀន, បច្ចេកទេសស៊ើបអង្កេតពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មគ្រឿងញៀន និងការវិភាគគ្រឿងញៀន, កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀនតាមព្រំដែនកម្ពុជា-ថៃ / កម្ពុជា-វៀតណាម, កិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន របស់គណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ, ការបណ្តុះបណ្តាលចំណេះដឹងជាមូលដ្ឋានពីគ្រឿងញៀន, ការបណ្តុះបណ្តាល បំប៉ន់ជំនាញស្តីពីការស្រាវជ្រាវ ស៊ើបអង្កេត និងនីតិវិធីរៀបចំ ឯកសារ សំណុំរឿង, ការបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់តាមប្រព័ន្ធកុំព្យូទ័រ, ការត្រួតពិនិត្យសារជាតុគីមីផ្សំ, ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធរាយការណ៍ស្វ័យប្រវត្តិនូវប្រតិបត្តិការសង្ស័យនានា រួមទាំងគ្រឿងញៀន, កិច្ចប្រតិបត្តិការសាច់ប្រាក់សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, ការអនុវត្តយន្តការ និងវិធានការស្វែងរកសកម្មភាពទាំងឡាយ ដែលអាចពាក់ព័ន្ធការជួញដូរគ្រឿងញៀនដោយប្រើប្រាស់ប្រព័ន្ធធនាគារ, វគ្គបណ្តុះបណ្តាលស្តីពីការប្រឆាំងនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម, ការត្រួតពិនិត្យគ្រឿងញៀនតាមអាកាសយានដ្ឋានអន្តរ-ជាតិ នៃបណ្តាប្រទេសអាស៊ាន ។

ក្រៅពីការងារបណ្តុះបណ្តាលសមត្ថភាព អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន ៖

- ✓ ទទួលសម្ភារសម្រាប់មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ដែលផ្តល់ដោយគម្រោង HAARP តាមរយៈអង្គការ FHI360 និងសម្ភារសម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ផ្តល់ដោយ UNODC តាមរយៈគម្រោង PATROL
- ✓ ទទួលសម្ភារពីកម្មវិធីគម្រោងកាត់បន្ថយគ្រោះថ្នាក់ (HAARP)
- ✓ ទទួលឧបករណ៍សម្រាប់ធ្វើតេស្តទឹកនោមរកសារធាតុញៀនពីក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ ចំនួន ៤.០០០ តេស្ត
- ✓ ចុះទៅពិនិត្យសម្ភារការិយាល័យ (BLO) កម្ពុជា-ថៃ / កម្ពុជា-ឡាវ / កម្ពុជា-វៀតណាម និងពិនិត្យសម្ភារសម្រាប់បណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ដោយប្រព័ន្ធកុំព្យូទ័រ ។

ផ្តើមចេញពីការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទ បានបន្តយកចិត្តទុកដាក់ចូលរួមសហការបង្ក្រាបបទល្មើសគ្រឿងញៀន សំដៅកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀនក្នុងឆ្នាំ២០១៤នេះ ទទួលបានលទ្ធផលដូចតទៅ ៖

- បទល្មើសគ្រឿងញៀន បង្ក្រាបបាន សរុប **១.៣៣៧** ករណី លើ ៨៨៩ ករណី នៃឆ្នាំ២០១៣ កើនឡើង ៥០,៣៩ %
- ជនសង្ស័យ ឃាត់ខ្លួនសរុប **៣.១៤២** នាក់ (ស្រី ៤២៥ នាក់) លើ ១.៨៣០ នាក់ នៃឆ្នាំ២០១៣ កើនឡើង ៧១,៦៩ %

ក្នុងចំនួនបទល្មើស **១.៣៣៧** ករណី ខាងលើគឺ :

- បទល្មើសបង្ក្រាបដោយ **សមត្ថកិច្ចនគរបាលជាតិ** មាន **៩៩៦** ករណី ឃាត់ខ្លួនជនសង្ស័យសរុប **២.២៣៥** នាក់ (ស្រី ៣០០ នាក់) ។

  ក្នុង ៩៩៦ ករណីនេះ មាន ៦ ករណី ដែលអគ្គស្នងការដ្ឋាននគរបាលជាតិ បានសហការជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករ, រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងអគ្គនាយកដ្ឋានកាំកុងត្រូល បង្ក្រាបនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងបញ្ញើរប្រៃសណីយ៍សាខាច្បារ

អំពៅ ដោយបានចាប់យកគ្រឿងញៀនប្រភេទ កូកាអ៊ីន ហេរ៉ូអ៊ីន និង សារធាតុគីមីផ្សំអេហ្វេទ្រីន ក្នុងចំនួនគួរកត់សំគាល់ ។

- បទល្មើសបង្ក្រាបដោយ **សមត្ថកិច្ចកងរាជអាវុធហត្ថ** មាន **៣៤១** ករណី, ឃាត់ខ្លួនជនសង្ស័យ **៩០៧** នាក់ (ស្រី ១២៥ នាក់) ។ ក្នុងចំនួន ៣៤១ ករណីនេះ មាន ១ ករណី ត្រូវបានបង្ក្រាបដោយកងទ័ពជើងទឹកមូលដ្ឋានដែនសមុទ្រទិសខេត្តកោះកុង ។

ក្នុងចំនួនជនសង្ស័យដែលបានឃាត់ខ្លួនទាំង ៣.១៤២ នាក់ មាន ១៣ សញ្ជាតិគឺ ជនជាតិ ខ្មែរ វៀតណាម ថៃ ឡាវ ចិន នីហ្សេរីយ៉ា អូស្ត្រាលី ហ្វីលីពីន រុស្ស៊ី សឹង្ហបុរី ម៉ាឡេស៊ី ណ័រវេស និង ឥណ្ឌូនេស៊ី ។

- ***វត្ថុតាងគ្រឿងញៀនសំខាន់ៗចាប់យក រួមមាន***

| ប្រភេទគ្រឿងញៀន | ២០១៤ | ២០១៣ | កើនឡើង | ថយចុះ |
|---|---|---|---|---|
| មេតំហ្វេតាមីនគ្រាប់ WY | ៨ គ.ក្រ ៧០៣ ក្រាម ០៩ | ១៧ គ.ក្រ ៣៣៤ ក្រាម ៩១ | | ៤៩,៧៩ % |
| មេតំហ្វេតាមីន ICE | ២៩ គ.ក្រ ០០៩ ក្រាម ៣៨ | ៣២ គ.ក្រ ៤៤៨ ក្រាម ៨២ | | ១០,៥៩ % |
| អ៊ិចស្តាស៊ី | ៣ គ.ក្រ ១៥៩ ក្រាម ៤៣ | គ្មាន | | |
| ហេរ៉ូអ៊ីន | ១ គ.ក្រ ៨៣៧ ក្រាម ៤៦ | ៣៨ គ.ក្រ ៣៣៧ ក្រាម ៦៨ | | ៩៥,២០ % |
| កូកាអ៊ីន | ៧ គ.ក្រ ៨៩០ ក្រាម ២០ | ១២ គ.ក្រ ៨៥១ ក្រាម | | ៣៨,៦០ % |
| កេតាមីន | ៦២០ ក្រាម ០៧ | ១.០១៦ ក្រាម | | ៣៨,៩៦ % |
| ដើមកញ្ឆា | ១២.៤១៥ ដើម | គ្មាន | | |
| កញ្ឆាក្រៀម | ១៩ គ.ក្រ ៩០១ ក្រាម ៦២ | ១៦៨ គ.ក្រ ៥៣៧ ក្រាម | | ៨៨,១៩ % |
| គ្រាប់ពូជកញ្ឆា | ៩ គ.ក្រ | គ្មាន | | |
| ប្រេងម្រះព្រៅភ្នំ | ១៣៩ ប៊ីដុង = ៥.២២០ គ.ក្រ | គ្មាន | | |
| តូលុយអែន | ១.៤៣២ គ.ក្រ | គ្មាន | | |
| អេហ្វេទ្រីន | ២៥ គ.ក្រ ៩៨៨ ក្រាម | គ្មាន | | |
| ម្សៅសង្ស័យគ្រឿងញៀន | ៣.៩៥៥ គ.ក្រ ៤៨ ក្រាម | គ្មាន | | |

- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធបទល្មើសគ្រឿងញៀន ដែលបានរឹបអូសបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត រួមមាន** : ម៉ូតូ ៥២៤ គ្រឿង, រថយន្ត ២៩ គ្រឿង, ប្រាក់កម្ពុជា ២៣៣.៥៥៨.៦៤០ រៀល, ប្រាក់ថៃ ៣.៤៤១ បាត, ប្រាក់អាមេរិក ៦០.៤១៥ ដុល្លារ, ប្រាក់វៀតណាម ១.៦៧៧.០០០ ដុង, ប្រាក់ចិន ១០០ យ័ន, ប្រាក់ឥណ្ឌូនេស៊ី ២៦.០០០ និងវត្ថុតាងមួយចំនួនទៀត ត្រូវបានបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ដើម្បីអនុវត្តតាមផ្លូវច្បាប់ (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២) ។
- **ជនជាប់ចោទចាប់តាមដីកា** មាន ៦៧ ដីកា មនុស្ស ៦៦ នាក់ (ស្រី ០៦ នាក់) ។

**ដោយឡែក** សំណុំរឿងបទល្មើសគ្រឿងញៀន ក្នុងដែនសមត្ថកិច្ចរបស់សាលាដំបូងរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ សៀមរាប ក្រចេះ កំពង់ធំ ព្រះសីហនុ ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ រតនគិរី ស្វាយរៀង តាកែវ កំពត សរុបមាន ១៧៣១ សំណុំរឿង (មិនទាន់មានតួលេខ ខេត្តកំពង់ឆ្នាំង

កោះកុង ស្ទឹងត្រែង មណ្ឌលគិរី ព្រៃវែង និង ខេត្តត្បូងឃ្មុំ) ដែលក្នុងនោះសំណុំរឿងជម្រះក្តីរួចមាន ១០៥០ សំណុំរឿង, កំពុងសាកសួរមាន ៦២៣ សំណុំរឿង និងមិនទាន់ចាត់ការមាន ៣៤៦ សំណុំរឿង ។

មន្ទីរពិសោធន៍គ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលសង្ស័យជាគ្រឿងញៀន បានចំនួន ១១០៧ សំណាក = ៩៣៩ ករណី ក្នុងនោះ ៖

- **សំណាកវិជ្ជមានសារធាតុញៀន** ១.០៤៣ សំណាក = ៩២០ ករណី គឺ :
  មេតំហ្វេតាមីន ICE ៧៧៥ សំណាក = ៧០ % មេតំហ្វេតាមីន WY ២២៥ សំណាក(២០,៣២ %)
  កេតាមីន ១៣ សំណាក (១,១៧ %) MDMA ១០ សំណាក (០,៩០ %)
  កញ្ឆា ៥ សំណាក (០,៤៥ %) ហេរ៉ូអ៊ីន ៤ សំណាក (០,៣៦ %)
  នីមេតាហ្សេប៉ាម ៣ សំណាក (០,២៧ %) ឌីយ៉ាហ្សេប៉ាម ៣ សំណាក (០,២៧ %)
  អេហ្វេឌ្រីន ២ សំណាក (០,១៨ %) កូកាអ៊ីន ២ សំណាក (០,១៨ %)
  តូលុយអែន ១ សំណាក (០,០៩ %)
- **សំណាកអវិជ្ជមានសារធាតុញៀន** ៦៤ សំណាក = ១៩ ករណី

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានណែនាំដល់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងក្រសួងសុខាភិបាល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ធ្វើការប្រមូលទិន្នន័យសារធាតុគីមីផ្សំ, វត្ថុធាតុដើមនិងឱសថដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលក្នុងឆ្នាំ២០១៤នេះ មានដូចតទៅ ៖

- **ក្រសួងឧស្សាហកម្ម និងសិប្បកម្ម** : សារធាតុក្នុងតារាង IV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (វត្ថុធាតុដើម) មានចំនួន ៥.៥១៧.០១៦ គ.ក្រ ៨០ ប៊ិត ៨.១៧៨ លីត្រ និង ៦៥ អំពូល
- **ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** : សារធាតុក្នុងតារាង IV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (វត្ថុធាតុដើម) មានចំនួន ៣.២៤៤.៩៩០ គ.ក្រ ១០.៥៤០ លីត្រ ២០០ ហ្គាឡុង និង ៣៦ ដប
- **ក្រសួងសុខាភិបាល** :
  ១. សារធាតុក្នុងតារាង II, III នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
    - វត្ថុធាតុដើម មានចំនួន ៨៣៨ គ.ក្រ និង ៥០០ ក្រាម
    - ទម្រង់ជាឱសថ មានចំនួន ១១៣ គ.ក្រ ១០.៣៦៥ ក្រាម ៥.៤៩៥,១២២ មិល្លីក្រាម និង ២.៣២៥ មីក្រូក្រាម
  ២. សារធាតុក្នុងតារាង IV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
    - វត្ថុធាតុដើម មានចំនួន ៧២៧,៥ គ.ក្រ
    - ទម្រង់ជាឱសថ : (ឱសថដែលមានផ្ទុកសារធាតុក្នុងតារាងឧបសម្ព័ន្ធ IV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន) មានចំនួន ២៦ គ.ក្រ ១៩០២ ក្រាម និង ៥២០ មិល្លីក្រាម (ដូចមានក្នុងតារាងឧបសម្ព័ន្ធ៣)

ក្រៅពីការងារប្រមូលទិន្នន័យសារធាតុគីមីផ្សំ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន ៖

- ចុះសិក្សាស្រាវជ្រាវករណីប្រេងម្រះព្រៅភ្នំ ដែលសមត្ថកិច្ចខេត្តពោធិ៍សាត់រកឃើញ និងចាប់យក ចំនួន ១៣៩ ប៊ីដុង ស្មើនឹង ៥.២២០ គ.ក្រ កាលពីថ្ងៃទី១៧, ១៨ និង ២៦ ខែសីហា ឆ្នាំ២០១៤
- រៀបចំពិធីប្រគល់ប្រេងម្រះព្រៅភ្នំ ចំនួន ១.៩១៣ គីឡូក្រាម ដែលសមត្ថកិច្ចខេត្តកំពង់ឆ្នាំងចាប់យក ជូនទៅ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- រៀបចំឯកសាររបាយការណ៍សំយោគពាក់ព័ន្ធនឹងការចរាចរ ការចាប់យកប្រេងម្រះព្រៅភ្នំ កន្លងមក
- រៀបចំកិច្ចប្រជុំជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីការប្រមូលព័ត៌មានពាក់ព័ន្ធការនាំចូលសារធាតុគីមីផ្សំ និងសារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ
- សហការជាមួយអង្គការ UNODC ដើម្បីបញ្ជូនសំណាកម្សៅល្អិតរមៀត ទៅធ្វើការវិភាគឱ្យដឹងច្បាស់ថាតើមានផ្ទុកនូវសារធាតុដែលអាចផ្សំផលិតជាគ្រឿងញៀនឬទេ
- ស្នើសុំទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីចេញដីកាប្រគល់សារធាតុគីមី ចំនួន ១៤ មុខ ទម្ងន់ ១៨ តោន ៩០០ គីឡូក្រាម ដែលសមត្ថកិច្ចអនុវត្តន៍ច្បាប់ចាប់យក និងរក្សាទុកនៅកំពង់ផែស្វយ័ត ខេត្តព្រះសីហនុ ជូនទៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីគ្រប់គ្រងបន្ត និងចាត់ចែងតាមសមត្ថកិច្ច ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តសម្របសម្រួលដើម្បីពង្រឹងយន្តការនៃកិច្ចសហប្រតិបត្តិការ ទ្វេភាគី ត្រីភាគី ជាមួយប្រទេសថៃ / ឡាវ / វៀតណាម តាមរយៈកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល សរុបបានចំនួន ០៥ លើកមានអ្នកចូលរួមសរុប ៧១ នាក់ (មន្ត្រីរបស់អគ្គលេខាធិការដ្ឋាន ១៧ នាក់, មន្ត្រីស្ថាប័នពាក់ព័ន្ធ ៥៤ នាក់) ។

បណ្តាកិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាលទាំងនោះរួមមាន កិច្ចប្រជុំអន្តរក្រសួងនៃអនុគណៈកម្មការសន្តិសុខ និងការបរទេសសម្រាប់តំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម, កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលចម្រុះនៃតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម លើកទី៩ និងកិច្ចប្រជុំពាក់ព័ន្ធ, កិច្ចប្រជុំទ្វេភាគីកម្ពុជា-ថៃ លើកទី៨ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន, កិច្ចប្រជុំទ្វេភាគី ត្រីភាគី ថ្នាក់រដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ឡាវ វៀតណាម លើកទី១៤ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន, វគ្គបណ្តុះបណ្តាលពង្រឹងកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន (រៀបចំដោយភាគីថៃ), វគ្គបណ្តុះបណ្តាលស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀន (រៀបចំដោយភាគីវៀតណាម) ។

**ដោយឡែក**

- ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង បានជួបប្រជុំជាមួយខេត្តតៃនិញ (វៀតណាម) ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន (ខាងភាគីកម្ពុជា មានសមាសភាពចូលរួម ៣៨ នាក់)
- ស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី បានជួបប្រជុំជាមួយស្នងការដ្ឋាននគរបាលខេត្តដាក់ឡាក់ (វៀតណាម) ដើម្បីបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន (ធ្វើនៅខេត្តមណ្ឌលគិរី ខាងភាគីកម្ពុជាមានចំនួន ៣៣ នាក់)
- ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានជួបប្រជុំការិយាល័យ BLO ប៉ោយប៉ែត ជាមួយការិយាល័យ BLO អារញ្ញប្រាថេត ខេត្តស្រះកែវ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន (ខាងភាគីកម្ពុជា មានសមាសភាពចូលរួម ១៦ នាក់)
- ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានរៀបចំកិច្ចប្រជុំថ្នាក់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) រវាងច្រកដូង និងច្រកប៉ូងណាំរ៉ន (ថៃ) ដើម្បីពិភាក្សាលើគម្រោងបណ្តុះបណ្តាលដល់មន្ត្រីនៃការិយាល័យ BLO
- ស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ បានប្រជុំរវាងការិយាល័យទំនាក់ទំនងព្រំដែន (BLO) ក្រុងសំរោង

ជាមួយការិយាល័យ (BLO) ស្រុកកាប់ធើន ខេត្តសុរិន (ថៃ) (ធ្វើនៅស្រុកកាប់ធើន ខាងកម្ពុជាមានអ្នកចូលរួម ១៥ នាក់) ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តសម្របសម្រួលជាមួយអង្គការ **UNODC** ដើម្បីពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការតាមរយៈយន្តការទ្វេភាគី ពហុភាគី ទាំងនៅក្នុងនិងក្រៅប្រទេស ជាមួយបណ្តាប្រទេសនៅក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ បានចំនួន **២៨** លើក មានមន្ត្រីចូលរួមសរុប **២៣១** នាក់ (អគ្គលេខាធិការដ្ឋាន ៧៧ នាក់, មន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ ១៥៤ នាក់) ។ បណ្តាកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលសំខាន់ៗ រួមមាន ៖

១. កិច្ចប្រជុំមន្ត្រីទំនាក់ទំនងស្តីពីគម្រោងថ្មីគាំទ្រភាពជាដៃគូនៃបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ, កិច្ចសម្របសម្រួលអន្តរជាតិដើម្បីទប់ស្កាត់និងប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន, កិច្ចប្រជុំក្រុមការងារអនុវត្តន៍ច្បាប់ត្រួតពិនិត្យគ្រឿងញៀនរបស់អាស៊ាន, កិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរបស់អង្គការសហប្រជាជាតិ **(CND)**, កិច្ចប្រជុំគណៈកម្មការប្រឹក្សាយោបល់ PATROL លើកទី៦, កិច្ចប្រជុំគណៈកម្មាធិការមន្ត្រីជាន់ខ្ពស់ នៃបណ្តាប្រទេសហត្ថលេខីស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀននៅក្នុងមហាអនុតំបន់ទន្លេមេគង្គ, កិច្ចប្រជុំក្រុមមន្ត្រីសម្របសម្រួលថ្នាក់កណ្តាលនិងពិគ្រោះយោបល់របស់ក្រុមអ្នកជំនាញផ្នែកអប់រំបង្ការគ្រឿងញៀន, កិច្ចប្រជុំ ASEAN-NARCO ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន, កិច្ចប្រជុំ GIZ/INI ស្តីពីការសន្ទនាក្រៅផ្លូវការអំពីគោលនយោបាយគ្រឿងញៀនអាស៊ាន ។

២. សិក្ខាសាលាស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមច្រកអាកាសយានដ្ឋានអន្តរជាតិ នៃបណ្តាប្រទេសអាស៊ានលើកទី៤, សិក្ខាសាលាអាស៊ានឆ្នាំ២០១៤ ស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀន, សិក្ខាសាលាតំបន់ស្តីពីកម្មវិធីបណ្តុះបណ្តាលការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន ។

៣. វគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ, ការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន, ការត្រួតពិនិត្យបទល្មើសគ្រឿងញៀន, វគ្គបណ្តុះបណ្តាលចល័តស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន តាមប្រព័ន្ធអេឡិចត្រូនិច ។

៤. សន្និសីទស្តីពីការអនុវត្តច្បាប់គ្រឿងញៀននៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក លើកទី១៩ និងសន្និសីទអនុវត្តន៍ច្បាប់មហាអនុតំបន់ទន្លេមេគង្គ ឆ្នាំ២០១៤ ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ដើម្បីពង្រឹងការអនុវត្តយុទ្ធសាស្ត្រពហុវិស័យកាន់តែមានប្រសិទ្ធភាព អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបន្តយកចិត្តទុកដាក់អនុវត្តបន្ថែមលើការងារមួយចំនួនទៀត មានដូចខាងក្រោម ៖

- ✓ រៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ✓ រៀបចំអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ✓ ចូលរួមកែសម្រួលសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- ✓ រៀបចំសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្ត-ក្រុង (រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចរួចហើយ)
- ✓ រៀបចំអនុក្រឹត្យស្តីពីនីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល និងគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាព

ញៀនគ្រឿងញៀន
- ✓ រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- ✓ រៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការបន្សាបនិងការព្យាបាលទាំងផ្លូវកាយ និងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន
- ✓ កែសម្រួលសមាសភាពរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO)
- ✓ សហការរៀបចំផែនការត្រួតពិនិត្យគ្រឿងញៀន របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ។

ជាមួយនេះ នៅក្នុងឱកាសសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៣និងទិសដៅការងារឆ្នាំ២០១៤ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានផ្តល់គ្រឿងឥស្សរិយយស ប័ណ្ណសរសើរ លិខិតសរសើរ ជូនដល់អង្គភាព និង បុគ្គល ដែលមានស្នាដៃនៅតាមក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និង គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តនូវ **គ្រឿងឥស្សរិយយស ២៨៦** គ្រឿង, **ប័ណ្ណសរសើរ លិខិតសរសើរ** របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន **៣៣៨** សន្លឹក ។

## IV. ការសន្និដ្ឋាន និងវាយតម្លៃ

អាស្រ័យដោយការអនុវត្តយុទ្ធសាស្ត្រពហុវិស័យស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលមានសកម្មភាពនិងលទ្ធផលដូចខាងលើ យើងបានធ្វើការសន្និដ្ឋាន និងវាយតម្លៃ ដូចតទៅ ៖

**១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន** ៖ ជារួម ដោយមានការចូលរួមយ៉ាងសកម្មពីគ្រប់មជ្ឈដ្ឋានសង្គម បានធ្វើឱ្យការងារផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀន ទាំងនៅក្នុងចំណោមមហាជនទូទៅ ទាំងនៅក្នុងក្រុមគោលដៅងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ ទទួលបានលទ្ធផលល្អប្រសើរ ជាពិសេសយើងធ្វើសកម្មភាពបានចំគោលដៅច្រើនជាងឆ្នាំ២០១៣ ។ ជាមួយនេះដែរ តាមរយៈគេហទំព័ររបស់អាជ្ញា ធរជាតិ ក៏មានប្រិយមិត្តអ្នកចូលអានក្នុងចំនួនគួរកត់សំគាល់ ។

ប៉ុន្តែចំណុចខ្វះខាតគឺ ឧបករណ៍ សម្ភារ ថវិកា សម្រាប់បំពេញការងារខាងលើ ជាពិសេសឯកសារផ្សព្វផ្សាយនៅមិនទាន់បានអភិវឌ្ឍន៍ឱ្យបានសមស្របទៅនឹងស្ថានភាពគ្រឿងញៀនបច្ចុប្បន្ន ។

**២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន** ៖ គម្រោង និងសកម្ម ភាពនានា ក្នុងការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ត្រូវបានពង្រឹង ទាំងកម្មវិធីរបស់រាជរដ្ឋាភិបាលក៏ដូចជាកម្មវិធីរបស់អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ ដោយផ្សារភ្ជាប់បញ្ហាគ្រឿងញៀននិងអេដស៍ ។ ការផ្តល់សេវាព្យាបាលថែទាំសុខភាពចំពោះអ្នករងគ្រោះដោយគ្រឿងញៀន នៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋនិងការព្យាបាលដោយផ្អែកលើ សហគមន៍តាមប្រព័ន្ធសុខាភិបាលដែលមានស្រាប់ ក៏ត្រូវបានលើកកម្ពស់តាមរយៈការបណ្តុះបណ្តាលសមត្ថភាពដល់បុគ្គលិកសុខាភិបាល គិលានុបដ្ឋាក-គិលានុបដ្ឋាយិកា នៃមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពនៅតាមពន្ធនាគារ រាជធានី-ខេត្តនានា ។

ប៉ុន្តែចំណុចខ្វះខាតគឺ ការព្យាបាលតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសព្វថ្ងៃ នៅមានការខ្វះខាតគ្រូពេទ្យជំនាញផ្នែកព្យាបាលអ្នកញៀនគ្រឿងញៀន និងបុគ្គលិកជំនាញផ្នែកស្តារនីតិសម្បទា ។ ទន្ទឹមនេះ មណ្ឌលសុខភាព

និងមន្ទីរពេទ្យបង្អែក ដែលបានបណ្តុះបណ្តាលសមត្ថភាពរួចហើយមួយចំនួន នៅមិនទាន់មានជនរងគ្រោះដោយសារគ្រឿងញៀនចូលទៅទទួលយកសេវាព្យាបាល ។ ជនរងគ្រោះ ក៏ដូចជាអាណាព្យាបាលនៃជនរងគ្រោះមួយចំនួន នៅមិនទាន់បានដឹងថា នៅតាមមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព នៅតាមសហគមន៍មានការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅឡើយ ។ យន្តការតាមដាន និងត្រួតពិនិត្យ នៅមិនទាន់មានច្បាស់លាស់សម្រាប់គាំទ្រដល់ការព្យាបាលតាមសហគមន៍, សម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសម្រាប់ការធ្វើសមាហរណកម្មអ្នកដែលបានចាកចេញពីគ្រឿងញៀន ពិសេសគឺគោលនយោបាយស្តីពីការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ :** សមត្ថភាពរបស់មន្ត្រីអនុវត្តន៍ច្បាប់នៅថ្នាក់ជាតិ កាន់តែត្រូវបានពង្រឹង តាមរយៈការបណ្តុះបណ្តាលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងការបណ្តុះបណ្តាលជំនាញ ។ ជាមួយនេះដែរ មន្ត្រីអនុវត្តន៍ច្បាប់របស់យើងក៏កាន់តែមានបទពិសោធន៍ និងយល់ដឹងខ្ពស់ពីល្បិចកលរបស់ក្រុមឧក្រិដ្ឋជនគួបផ្សំនឹងការប្រើប្រាស់កម្លាំងសរុបបានល្អ ធ្វើឱ្យការទប់ស្កាត់និងបង្ក្រាបបានច្រើនករណីនិងចំគោលដៅ ។ ទន្ទឹមនេះ កិច្ចសហការរវាងស្ថាប័នតុលាការ និងស្ថាប័នអនុវត្តន៍ច្បាប់មានភាពរលូន ធ្វើឱ្យការជម្រះក្តីបទល្មើសគ្រឿងញៀនមួយចំនួនធំអនុវត្តបានឆាប់រហ័ស ។

ចំណុចខ្វះខាតគឺ ការពង្រឹងសមត្ថភាព ភាគច្រើនធ្វើបានតែនៅថ្នាក់ជាតិ ឯនៅថ្នាក់ក្រោមជាតិ ការបណ្តុះបណ្តាលនៅមានកម្រិតនៅឡើយ ជាពិសេសការបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់នៅថ្នាក់ប៉ុស្តិ៍រដ្ឋបាលមូលដ្ឋាន គឺយើងធ្វើមិនទាន់បានទូលំទូលាយ ។ មធ្យោបាយដែលមានគុណភាពសម្រាប់ជួយដល់កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀននៅមានការខ្វះខាត ។ មន្ត្រីអនុវត្តន៍ច្បាប់នៅថ្នាក់មូលដ្ឋានមួយចំនួនតូច នៅមិនទាន់មានការទទួលខុសត្រូវក្នុងការបង្ក្រាបបទល្មើស ដែលកើតឡើងនៅក្នុងមូលដ្ឋានរបស់ខ្លួន, ខ្លះទៀតខ្វះភាពស្មោះត្រង់ និងខ្វះមនសិការវិជ្ជាជីវៈ, ចំណេះដឹងទូទៅ របស់មន្ត្រីអនុវត្តន៍ច្បាប់នៅមានកម្រិត ។ ការកសាងលិខិតបទដ្ឋានគតិយុត្តិនានា សម្រាប់បម្រើដល់ការអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅមានភាពយឺតយ៉ាវ ។ ជាមួយនេះ ដោយសារនិន្នាការនៃការវិវឌ្ឍប្រែប្រួលនៃបញ្ហាគ្រឿងញៀននៅក្នុងសកលលោកនិងក្នុងតំបន់ដែលមិនទាន់មានការថយចុះ បានជះឥទ្ធិពលមកលើកម្ពុជាដែលជាប្រទេសនៅខ្វះបទពិសោធន៍ និងមិនដែលជួបប្រទះនូវសកម្មភាពដឹកជញ្ជូនគ្រឿងញៀនឆ្លងទ្វីប, ការបញ្ជាទិញគ្រឿងញៀនតាមប្រព័ន្ធ អ៊ីនធឺណែត, ការផ្ញើតាមប្រៃសណីយ៍ និងវិធីសាស្ត្រលាក់បាំងគ្រឿងញៀនប្លែកៗ ។ បណ្តាខេត្តភាគឦសាននៅតែជាខេត្តដែលបន្តមានការហូរចូលគ្រឿងញៀនខុសច្បាប់ ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ :** ជារួម ដោយមានកិច្ចសហការល្អជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ យើងគ្រប់គ្រងបានជាប់ជាប្រចាំនូវទិន្នន័យសារធាតុគីមីផ្សំដែលបានអនុញ្ញាតឱ្យនាំចូល ។ តាមរយៈការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់របស់យើងកាន់តែមានបទពិសោធន៍ និងចេះសង្ស័យពីសារធាតុគីមីផ្សំមួយចំនួន ព្រមទាំងទប់ស្កាត់បានទាន់ពេលតាំងពីនៅតំបន់ព្រំដែន បង្ការបានការបង្វែរយកមកសំយោគផលិតទៅជាគ្រឿងញៀន ។

ប៉ុន្តែចំណុចខ្វះខាតគឺ ការត្រួតពិនិត្យសារធាតុគីមីផ្សំ នៅមិនទាន់មានយន្តការច្បាស់លាស់ ធ្វើឱ្យការគ្រប់គ្រងតាមដានការចរាចរ ការប្រើប្រាស់សារធាតុគីមីផ្សំ (បរិមាណដែលប្រើប្រាស់រួចនិងសន្និធិ) ទាំងក្នុងវិស័យឧស្សាហកម្ម សិប្បកម្ម និងសុខាភិបាល ក្តាប់មិនទាន់បានណែន ។ ព័ត៌មានពាក់ព័ន្ធនឹងសារធាតុគីមីផ្សំ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានមិនទាន់គ្រប់គ្រាន់សម្រាប់បម្រើឱ្យការត្រួតពិនិត្យ ការគ្រប់គ្រង ការទប់ស្កាត់នូវការបង្វែរសារធាតុគីមី

ផ្សំយកមកសំយោគផលិតជាគ្រឿងញៀន ។ ការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យសារធាតុគីមីផ្សំ ដល់សមត្ថកិច្ចពាក់ព័ន្ធ និងបុគ្គលិកក្រុមហ៊ុនឧស្សាហកម្មគីមី នៅមានកម្រិត ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន** : ជារួម កិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជា-ថៃ កម្ពុជា-ឡាវ និង កម្ពុជា-វៀតណាម យើងបានសហការក្នុងការទប់ស្កាត់ និងត្រួតពិនិត្យបទល្មើសគ្រឿងញៀនឆ្លងកាត់ព្រំដែនបានល្អប្រសើរ ។ កម្ពុជា ថៃ ឡាវ និង វៀតណាម បានប្តេជ្ញាចិត្តខ្ពស់ក្នុងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់តំបន់ព្រំដែន ដើម្បីធ្វើឱ្យតំបន់ព្រំដែនក្លាយជាតំបន់អភិវឌ្ឍន៍មានសុខសន្តិភាព និងចៀសឆ្ងាយពីការគំរាមកំហែងដោយបញ្ហាគ្រឿងញៀន ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា** : ទោះបីអង្គការអន្តរជាតិក៏ដូចជាប្រទេសម្ចាស់ជំនួយមួយចំនួនបានជួបនូវវិបត្តិហិរញ្ញវត្ថុ ធ្វើឱ្យគម្រោងនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនមួយចំនួន ដែលបានព្រមព្រៀងជាមួយកម្ពុជា ត្រូវបានកាត់បន្ថយក៏ពិតមែន ប៉ុន្តែយើងបានខិតខំពង្រឹងខ្លួនឯងជាបន្តបន្ទាប់ និងម្ចាស់ការបានលើការងារត្រួតពិនិត្យគ្រឿងញៀននៅទូទាំងប្រទេស ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** : ជារួមទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ បាននិងកំពុងយកចិត្តទុកដាក់បង្កើតនិងពង្រឹងយន្តការក្នុងការត្រួតពិនិត្យគ្រឿងញៀនតាមយុទ្ធសាស្ត្រពហុវិស័យ ។ សមត្ថភាពនិងប្រសិទ្ធភាពនៃស្ថាប័នសេនាធិការត្រូវបានលើកកម្ពស់និងជំរុញឱ្យអនុវត្តនូវផែនការជាតិ ៣ ឆ្នាំស្តីពីការត្រួតពិនិត្យគ្រឿងញៀន (២០១៣-២០១៥), អនុវត្តនូវគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន និងអនុវត្តនូវ គោលនយោបាយភូមិឃុំមានសុវត្ថិភាព ទទួលបានលទ្ធផលល្អគួរកត់សំគាល់ ។

ប៉ុន្តែការងារនេះ ក៏នៅមានចំណុចខ្វះខាតមួយចំនួនផងដែរ ជាអាទិ៍ អង្គភាពទទួលខុសត្រូវលើកិច្ចការគ្រឿងញៀន របស់ក្រសួង ស្ថាប័នមួយចំនួន នៅមិនទាន់អនុវត្តឱ្យបានសកម្ម និងប្រកបដោយគុណភាពខ្ពស់, លេខាធិការដ្ឋាននៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីខេត្តមួយចំនួន បានដំណើរការការងាររបស់ខ្លួនក៏ពិតមែន តែគ្មានផែនការត្រួតពិនិត្យគ្រឿងញៀនច្បាស់លាស់ ។ កន្លែងខ្លះទៀត យន្តការពហុវិស័យក្នុងការត្រួតពិនិត្យគ្រឿងញៀននៅមិនទាន់គ្រប់គ្រាន់ ។ ខេត្តខ្លះនៅមិនទាន់បានបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ទៅដល់ថ្នាក់ស្រុក ក្រុង ។

ជារួម ព័ត៌មានពហុវិស័យស្តីពីគ្រឿងញៀននៅ មិនទាន់មានគ្រប់គ្រាន់សម្រាប់បម្រើឱ្យកិច្ចប្រតិបត្តិការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀន ។

## V. ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៥

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ សម្រាប់ឆ្នាំ២០១៥ នេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តដាក់ចេញនូវទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ដូចខាងក្រោម :

*១.* ជំរុញការផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាពជាប្រចាំនិងចំគោលដៅមុខសញ្ញាប្រឈមនានា និងចលនាឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋានជាតិ-អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល អង្គការសាសនា វិស័យឯកជន សំដៅកាត់បន្ថយតម្រូវការ និងចេះបដិសេធគ្រឿងញៀន តាមគ្រប់រូបភាព គ្រប់ពេលវេលា និងគ្រប់ទីកន្លែង ។

*២.* ពង្រឹងសមត្ថភាពមណ្ឌលបណ្តោះអាសន្ន និងពង្រីកកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនផ្អែកលើសហគមន៍

ដោយប្រើប្រាស់ប្រព័ន្ធសុខាភិបាល និងប្រព័ន្ធសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានស្រាប់ ។ ពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានា អង្គការជាតិ អន្តរជាតិ និងវិស័យឯកជន ដើម្បីអនុវត្តតាមតួនាទីភារ-កិច្ច បន្សាប ព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មចំពោះអ្នកជួរស្រាលពីគ្រឿងញៀនទៅក្នុងគ្រួសារនិងសហគមន៍វិញ ព្រមទាំងមានវិធានការបន្តថែទាំសុខភាព សុខុមាលភាពអ្នកដែលបានចាកចេញពីគ្រឿងញៀន ជាពិសេស ស្ត្រី និង កុមារ ដើម្បីរួមចំណែកថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ធ្វើឱ្យភូមិ-ឃុំមានសុវត្ថិភាព ព្រមទាំងបន្តពង្រឹងកិច្ចសហប្រតិបត្តិការ រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអង្គការជាដៃគូដើម្បីដោះស្រាយបញ្ហាគ្រឿងញៀន និងមេរោគអេដស៍/ជំងឺអេដស៍ ដោយប្រើប្រាស់ធនធានឱ្យបានសមស្រប និងមានប្រសិទ្ធភាព ។

៣. ចាត់វិធានការគ្រប់បែបយ៉ាងតាមផ្លូវច្បាប់ និង រដ្ឋបាល ដើម្បីប្រឆាំងការផលិត ការដាំដុះ ការចម្រាញ់ ការចរាចរជួញដូរ ការស្តុកទុក និងប្រើប្រាស់គ្រឿងញៀន ចាប់ពីរូបភាពតូចតាចរហូតដល់រូបភាពធំៗ ព្រមទាំងលើកកម្ពស់គុណភាពនៃការអនុវត្តច្បាប់ ដើម្បីបំផ្លាញអង្គការចាត់តាំងឧក្រិដ្ឋជនគ្រឿងញៀនឆ្លងដែន ដោយសហការជិតស្និទ្ធជាមួយប្រទេសជិតខាង និងអន្តរជាតិ ដើម្បីរួមគ្នាបង្ក្រាបឧបាយកលថ្មីរបស់ពួកឧក្រិដ្ឋជនគ្រឿងញៀន ពង្រឹងការយល់ដឹង សមត្ថភាព ឆន្ទៈ គុណធម៌ វិជ្ជាជីវៈនិងការទទួលខុសត្រូវនៃស្ថាប័នអនុវត្តន៍ច្បាប់សំដៅបង្កើនគុណភាព និងកាត់បន្ថយភាពអសកម្មនានា ដែលជាការមិនស្មោះត្រង់ចំពោះវិជ្ជាជីវៈ និងការទទួលខុសត្រូវ ។

៤. បង្កើនកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការគ្រប់គ្រង ត្រួតពិនិត្យសារធាតុគីមីផ្សំ ដែលនាំចូលស្របច្បាប់ និងមិនស្របច្បាប់ ព្រមទាំងវត្ថុធាតុដើម ឬសារធាតុផ្សំមួយចំនួនទៀត ដើម្បីបង្ការ ការបង្វែរ និងទប់ស្កាត់សារធាតុទាំងនោះកុំឱ្យយកមកសំយោគផលិតទៅជាគ្រឿងញៀនខុសច្បាប់ ។

៥. បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន តាមគ្រប់រូបភាព សំដៅជំរុញយន្តការភូមិ-ឃុំបៃតង គ្មានគ្រឿងញៀននៅតាមតំបន់ព្រំដែន និងពង្រឹងយន្តការការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

៦. បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីពង្រឹងនិងពង្រីកកាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង និងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីគ្រឿងញៀន និងបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានា ដើម្បីស្វែងរកការគាំទ្រសម្រាប់សកម្មភាពត្រួតពិនិត្យគ្រឿងញៀន ។

៧. ពង្រឹងស្ថាប័នសេនាធិការ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អាជ្ញាធរពាក់ព័ន្ធទាំងអស់ ដើម្បីពង្រីកលទ្ធភាពអនុវត្តយុទ្ធសាស្ត្ររបស់អាជ្ញាធរជាតិឱ្យមានប្រសិទ្ធភាព និងអនុវត្តគោលយោបាយលើកទឹកចិត្តដល់អង្គភាពបុគ្គលដែលមានស្នាដៃក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជំរុញចលនាប្រឡងប្រណាំងតាមខ្លឹមសារយុទ្ធសាស្ត្រពហុវិស័យស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## VI. ផែនការសកម្មភាពអនុវត្តទិសដៅការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៥

ដើម្បីអនុវត្តបានតាមទិសដៅខាងលើ និងផ្អែកតាមផែនការជាតិ៣ឆ្នាំ (២០១៣-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដាក់ចេញនូវផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀនសម្រាប់ឆ្នាំ២០១៥ ដូចខាងក្រោម :

### *១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ បដិសេធគ្រឿងញៀន*

១.១. បន្តបញ្ជ្រាបខ្លឹមសារអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ទៅក្នុងពិធីបុណ្យជាតិ-អន្តរជាតិធំៗ

១.២. បន្តរៀបចំកម្មវិធីប្រឡងតែងកំណាព្យ និងប្រឡងគូរគំនូរអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមសាលារៀន នៅតាមរាជធានី ខេត្តគោលដៅ និងបណ្តាខេត្តនៅជាប់ព្រំដែនកម្ពុជា-ឡាវ

១.៣. ផលិតឯកសារផ្សព្វផ្សាយអប់រំ ពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន

១.៤. បង្កើនការអប់រំតាមប្រព័ន្ធផ្សព្វ ផ្សាយ (វិទ្យុជាតិ វិទ្យុរាជធានី ខេត្ត និងស្ថានីយទូរទស្សន៍នានា) ពាក់ព័ន្ធនឹងការងារអប់រំ បង្ការ ទប់ស្កាត់ បទល្មើសគ្រឿងញៀន ការព្យាបាល និងស្តារនីតិសម្បទា

១.៥. បង្កើនការអប់រំផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហាគ្រឿងញៀន តាមរយៈកម្មវិធីនាទីព្រះពុទ្ធសាសនា ផ្សារភ្ជាប់នឹងសង្គម

១.៦. បំប៉នគ្រូឧទ្ទេសនៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត ពីការអប់រំបំណិនជីវិតស្តីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ដោយរួមបញ្ចូលទាំងការអប់រំពីជំងឺអេដស៍ និងគ្រឿងញៀន

១.៧. ធ្វើការអប់រំពីបំណិនជីវិតស្តីពីសុខភាពបន្តពូជ និងសុខ ភាពផ្លូវភេទ ដោយរួមបញ្ចូលទាំងការអប់រំពីជំងឺអេដស៍ និងគ្រឿងញៀន នៅតាមសកលវិទ្យាល័យក្នុងរាជ ធានីភ្នំពេញ ព្រមទាំងបញ្ជាពាក់ព័ន្ធ ដល់គ្រូអក្ខរកម្ម និងគ្រូនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍

១.៨. ធ្វើការបំប៉នគ្រូនៅតាមវិទ្យាល័យគោលដៅមួយចំនួន ពីការអប់រំបំណិនជីវិតស្តីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ដោយរួមបញ្ចូលទាំងការអប់រំពីជំងឺអេដស៍ និងគ្រឿងញៀន តាមរយៈកម្មវិធីអេឡិចត្រូនិច (E-learning)

១.៩. រៀបចំផលិតបន្ថែមនូវ ស្ព័ត (Spot) អប់រំពីបញ្ហាគ្រឿងញៀន និង ស្ទីកឃ័រ (Sticker) ផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀន អេដស៍ ការជួញដូរមនុស្ស និងការប្រើប្រាស់អាវុធជាតិផ្ទុះ

១.១០. បន្តរៀបចំសាលារៀនបៃតង (សាលារៀនគ្មានគ្រឿងញៀន)

១.១១. បញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនទៅក្នុងកម្មវិធីសម្តែងសិល្បៈ ការប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុនឯកជននានា, កម្មវិធីប្រដាល់ និងបាល់ទាត់, កម្មវិធីល្ខោននិយាយ, កម្មវិធីមហោស្រពចម្រៀងសម័យថ្នាក់ជាតិ, មហោស្រពប្រឡងចម្រៀងកុមារ ជាដើម ។ល។ និង ។ល។

១.១២. ពង្រឹងការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ និងបន្តជំរុញចលនាប្រឡងប្រណាំង " ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាកម្មល្អ "

១.១៣. បញ្ជ្រាបការអប់រំទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនដល់កម្មករ-និយោជិត ។

## ២. *ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន*

២.១. បន្តស្វែងរកការគាំទ្រផ្នែកសម្ភារ និងការបណ្តុះបណ្តាលធនធានមនុស្សលើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនពីបណ្តាប្រទេសម្ចាស់ជំនួយនានា

២.២. បន្តស្វែងរកដៃគូអភិវឌ្ឍន៍វិស័យយុវនីតិសម្បទា និងពង្រឹងសមត្ថភាពមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម

២.៣. បន្តកៀរគរធនធានថវិកាសម្រាប់ការកសាងមជ្ឈមណ្ឌលជាតិ បណ្តុះបណ្តាលវិជ្ជាជីវៈ នៅតំបន់កែវផុស ខេត្តព្រះសីហនុ

២.៤. បន្តពង្រឹងការផ្តល់សេវាផ្នែកវេជ្ជសាស្ត្រនៅក្នុងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ

២.៥. បន្តការរៀបចំវគ្គបណ្តុះបណ្តាលបន្ថែមនូវធនធានគ្រូពេទ្យផ្នែកវេជ្ជសាស្ត្រ ផ្នែកចិត្តសាស្ត្រ សម្រាប់មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព នៅតាមរាជធានី ខេត្តគោលដៅ ដើម្បីផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍

២.៦. បន្តអនុវត្តផែនការស្តីពីការអភិវឌ្ឍសេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀន

២.៧. ពង្រឹងយន្តការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ជាមូលដ្ឋាន តាមប្រព័ន្ធសុខាភិបាល

២.៨. បន្តការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

២.៩. បង្កើនសកម្មភាពអប់រំណែនាំដល់អ្នករងគ្រោះដោយសារគ្រឿងញៀន ឱ្យស្ម័គ្រចិត្តទៅទទួលយកសេវាបន្សាប ព្យាបាលភាពញៀនគ្រឿងញៀន នៅកន្លែងផ្តល់សេវាដែលបានរៀបចំរួច

២.១០. បន្តការផលិតស្លាកសញ្ញា ដើម្បីដាក់បង្ហាញនៅតាមមណ្ឌលសុខភាពដែលបានរៀបចំរួច ក្នុងរាជធានីភ្នំពេញ និងជំរុញការរៀបចំកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅរាជធានីភ្នំពេញ ឱ្យបានឆាប់រហ័ស

២.១១. ធ្វើការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយថែមទៀត អំពីកម្មវិធីផ្តល់សេវាព្យាបាលនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងការផ្តល់សេវាព្យាបាលរបស់អង្គការមិត្តសំឡាញ់

២.១២. ធ្វើការពន្យល់ណែនាំ ដើម្បីលើកកម្ពស់ការយល់ដឹងពីការអនុវត្តកម្មវិធីម្ទុល/ស៊ីរ៉ាំង

២.១៣. រៀបចំកិច្ចប្រជុំ ពិភាក្សាជាមួយតំណាងអយ្យការ និង តុលាការ ពាក់ព័ន្ធនឹងការចោទប្រកាន់អ្នកប្រើប្រាស់គ្រឿងញៀន ឱ្យទៅទទួលយកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក

២.១៤. បន្តរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីសុខាភិបាលពន្ធនាគារ លើការងារព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមប៉ុស្តិ៍សុខភាពពន្ធនាគារ ។

## ៣. *ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់*

៣.១. បន្តជំរុញវិធានការទប់ស្កាត់ បង្ក្រាបបទល្មើសគ្រឿងញៀន និងសារធាតុគីមីផ្សំ ខុសច្បាប់ តាមច្រកទ្វារព្រំដែនអន្តរជាតិ ទាំងផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស និងប្រៃសណីយ៍ ឱ្យកាន់តែ មានប្រសិទ្ធភាព

៣.២. បន្តពង្រឹងសមត្ថភាព និងរចនាសម្ព័ន្ធទទួលកិច្ចការរដ្ឋបាលរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ដើម្បីធានាទាំងគុណភាព និងប្រសិទ្ធភាពការងារ

៣.៣. បន្តផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ពិសេសនីតិវិធីក្នុងការស៊ើបអង្កេត ការប្រមូលវត្ថុតាងគ្រឿងញៀន និងនីតិវិធីក្នុងការកសាងសំណុំរឿងបញ្ជូនទៅតុលាការ

៣.៤. សហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីពង្រឹងការត្រួតពិនិត្យបញ្ញើប្រៃសណីយ៍ និងបញ្ញើតាមរយៈក្រុមហ៊ុនបញ្ញើរហ័សនានា

៣.៥. លើកកម្ពស់ការប្រមូលទិន្នន័យព័ត៌មានស៊ើបអង្កេត ដើម្បីឈានទៅទប់ស្កាត់បានជាមុននូវការផលិត ការជួញដូរ ការចរាចរគ្រឿងញៀននៅតាមតំបន់គោលដៅសំខាន់ៗ

៣.៦. ជំរុញការស៊ើបអង្កេតសកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម កើតចេញពីការជួញដូរគ្រឿងញៀន

៣.៧. បន្តបើកវគ្គបណ្តុះបណ្តាលមន្ត្រី BLO និងមន្ត្រីអនុវត្តន៍ច្បាប់នានា ពីជំនាញត្រួតពិនិត្យគ្រឿងញៀនតាមប្រព័ន្ធកុំព្យូទ័រ (CBT)

៣.៨. រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន តាមប្រព័ន្ធអេឡិចត្រូនិច (E-Learning)

៣.៩. រៀបចំផលិតវីដេអូឯកសារ សម្រាប់ការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់

៣.១០. រៀបចំបង្កើតក្រុមការងារទប់ស្កាត់ការចរាចរគ្រឿងញៀនឆ្លងកាត់តាមច្រកអាកាសយានដ្ឋានអន្តរជាតិ

៣.១១. រៀបចំវគ្គបណ្តុះបណ្តាល បំប៉នជំនាញស្តីពីការស្រាវជ្រាវ ស៊ើបអង្កេត និងការកសាងឯកសារ សំណុំរឿងនីតិវិធីក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន ដល់មន្ត្រីនគរបាលដែលមានភារកិច្ចពាក់ព័ន្ធ នៅតាមបណ្តាខេត្តគោលដៅ

៣.១២. បន្តជំរុញការធ្វើសម្រង់ទិន្នន័យសំណុំរឿងបទល្មើសគ្រឿងញៀនក្នុងដែនសមត្ថកិច្ចតុលាការ

៣.១៣. រៀបចំវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់សមត្ថកិច្ចពាក់ព័ន្ធ និងភ្នាក់ងារដែលបម្រើការងារនៅក្នុងអាកាសយានដ្ឋានអន្តរជាតិនានា

៣.១៤. រៀបចំវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់កងយោធពលខេមរភូមិន្ទ

៣.១៥. ធ្វើសម្រង់ទិន្នន័យឧប្បត្តិហេតុនៃបទល្មើសនានាក្នុងឆ្នាំ២០១៤ ដែលបានកើតឡើងដោយសារគ្រឿងញៀន និងបទល្មើសគ្រឿងញៀន ដោយបញ្ជាក់ពីមុខរបរជនល្មើសឱ្យបានច្បាស់លាស់ ។

## ៤. *ការត្រួតពិនិត្យសារធាតុគីមីផ្សំ*

៤.១. បន្តជំរុញនិងពង្រឹងយន្តការត្រួតពិនិត្យ គ្រប់គ្រងការចរាចរ ការប្រើប្រាស់សារធាតុគីមីផ្សំ ទាំងក្នុងវិស័យ

សុខាភិបាល និង វិស័យឧស្សាហកម្ម ដែលក្នុងនោះរួមមាន :

- គ្រប់គ្រងតាមដានការចេញលិខិតបញ្ជាក់មុខសញ្ញាប្រើប្រាស់ និងអាជ្ញាប័ណ្ណនាំចូល-នាំចេញសារធាតុគីមីផ្សំ និងការប្រើប្រាស់សៀវភៅបន្ទុក
- គ្រប់គ្រងតាមដាន ការចរាចរ ការប្រើប្រាស់សារធាតុគីមីផ្សំ ក្នុងវិស័យសុខាភិបាល និងវិស័យឧស្សាហកម្ម នៅក្នុងស្រុក (បរិមាណដែលប្រើប្រាស់រួច និង សន្និធិ)
- ចែករំលែកព័ត៌មានពាក់ព័ន្ធការត្រួតពិនិត្យគ្រប់គ្រងសារធាតុគីមីផ្សំទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

៤.២. បណ្តុះបណ្តាលជំនាញត្រួតពិនិត្យសារធាតុគីមីផ្សំ ដល់មន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធនិងបុគ្គលិកក្រុមហ៊ុនឧស្សាហកម្មគីមីនៅតាមគោលដៅ ដើម្បីចូលរួមធ្វើសកម្មភាពបង្ការការបង្វែរសារធាតុគីមីផ្សំពីជំនួញស្របច្បាប់ ទៅផលិតជាគ្រឿងញៀនខុសច្បាប់

៤.៣. ពង្រឹងយន្តការនៃការផ្តល់ព័ត៌មានជាមុនពីការនាំចូល-នាំចេញសារធាតុគីមីផ្សំ

៤.៤. រៀបចំឯកសារសម្រាប់បណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការស៊ើបអង្កេតការចរាចរសារធាតុគីមីផ្សំ និងមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់

៤.៥. បន្តការរៀបចំប្រកាសស្តីពីការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម

៤.៦. សិក្សាស្រាវជ្រាវប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ដើម្បីដាក់បញ្ចូលទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

៤.៧. រៀបចំឯកសាររបាយការណ៍សំយោគពាក់ព័ន្ធនឹងការចរាចរ ការរឹបអូសប្រេងម្រះព្រៅភ្នំ កន្លងមក ។

## ***៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន***

៥.១. បន្តជំរុញការរៀបចំយន្តការភូមិ ឃុំ បៃតងគ្មានគ្រឿងញៀន នៅតាមបណ្តោយព្រំដែន និងជ្រើសរើសភូមិ ឃុំ អាទិភាពសម្រាប់ការអនុវត្តដកបទពិសោធន៍ ភូមិ ឃុំ បៃតង នៅតាមបណ្តោយព្រំដែន ដើម្បីកំណត់បានជាគោលដៅក្នុងការអនុវត្តកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនជាមួយប្រទេសជិតខាង

៥.២. ពង្រឹងយន្តការដោះស្រាយ និងសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី និងត្រីភាគីជាមួយប្រទេសជិតខាង ដើម្បីស្វែងរកការគាំទ្រសម្រាប់សកម្មភាពត្រួតពិនិត្យគ្រឿង ញៀន

៥.៣. រៀបចំកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែនលើបញ្ហាគ្រឿងញៀន (BLOs) ឱ្យបានទៀងទាត់ជាមួយប្រទេសជិតខាង

៥.៤. ពង្រឹងសមត្ថភាពរបស់មន្ត្រីដែលធ្វើការនៅតាមការិយាល័យ (BLOs) នីមួយៗ ពង្រឹងយន្តការដោះស្រាយ និងសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី និងត្រីភាគី ជាមួយប្រទេសជិតខាង ដើម្បីស្វែងរកការគាំទ្រសម្រាប់សកម្មភាពត្រួតពិនិត្យគ្រឿងញៀន

៥.៥. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត ត្រូវដឹកនាំកិច្ចប្រតិបត្តិការរបស់ការិយាល័យ (BLOs) ហើយត្រូវរាយការណ៍មកអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣

៥.៦. ពង្រឹងយន្តការនៃកិច្ចសហប្រតិបត្តិការទ្វេភាគីរបស់ការិយាល័យ (BLOs) កម្ពុជា-ថៃ / កម្ពុជា-ឡាវ និង

កម្ពុជា-វៀតណាម

៥.៧. សម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ប្រទេសវៀតណាម និង ឡាវ ដើម្បីរៀបចំដំណើរទស្សនកិច្ចជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.៣ ។

## *៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា*

៦.១. រៀបចំសិក្ខាសាលា ស្តីពីការអនុវត្តអនុសញ្ញារបស់អង្គការសហប្រជាជាតិទាំង៣ ស្តីពីគ្រឿងញៀន (១៩៦១,១៩៧១,១៩៨៨)

៦.២. បន្តការកៀរគរបណ្តាប្រទេសផ្តល់ជំនួយ និងដៃគូអភិវឌ្ឍន៍នានា ឱ្យគាំទ្រសកម្មភាពត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា ទាំងក្នុងរូបភាពទ្វេភាគី និងពហុភាគី

៦.៣. ចូលរួមគ្រប់វេទិកាទាំងក្នុងតំបន់ និងអន្តរជាតិ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការទប់ស្កាត់ការជួញដូរគ្រឿងញៀនខុសច្បាប់ ឆ្លងកាត់កម្ពុជាទៅកាន់បណ្តាប្រទេសនានាក្នុងតំបន់

៦.៤. ចូលរួមក្នុងយន្តការត្រួតពិនិត្យគ្រឿងញៀនជាមួយបណ្តាប្រទេសអាស៊ាន

៦.៥. បង្កើនកិច្ចសហការជាមួយអង្គការ UNODC ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន តាមយន្តការប្រទេសមហាអនុតំបន់ទន្លេមេគង្គ

៦.៦. ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនជាមួយប្រទេសនានា នៅលើសកលលោក

៦.៧. ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនជាមួយនឹងអង្គការជាតិ និងអន្តរជាតិនានា នៅក្នុងតំបន់ និងសកលលោក ។

## *៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ*

***៧.១.*** រៀបចំកិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឆ្នាំ២០១៤ ដើម្បីត្រួតពិនិត្យលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៤ និងទិសដៅការងារ ឆ្នាំ២០១៥

***៧.២.*** រៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ២០១៥

***៧.៣.*** បន្តការរៀបចំព្រះរាជក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

***៧.៤.*** ជំរុញការរៀបចំអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

***៧.៥.*** ជំរុញការរៀបចំអនុក្រឹត្យស្តីពី នីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល និងគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន

***៧.៦.*** ជំរុញការរៀបចំសេចក្តីប្រកាសអន្តរក្រសួងស្តីពី ការបន្សាបនិងការព្យាបាលទាំងផ្លូវកាយ និងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន

***៧.៧.*** ជំរុញការរៀបចំអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

***៧.៨.*** ជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ឱ្យអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀន

***៧.៩.*** តាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការជាតិ ៣ ឆ្នាំ (២០១៣-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ពាក់កណ្តាលអាណត្តិ

***៧.១០.*** កសាងផែនការជាតិ ៣ ឆ្នាំបន្ត (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

***៧.១១.*** ជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ដើម្បីពង្រឹងសមត្ថភាពសេនាធិការក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ទៅដល់ថ្នាក់ ខណ្ឌ ស្រុក ក្រុង ឃុំ សង្កាត់គោលដៅ ។

ក្រៅពីផែនការសកម្មភាពអនុវត្តទិសដៅការងារត្រួតពិនិត្យគ្រឿងញៀនខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននឹងត្រៀមគ្រប់លក្ខណៈសម្បត្តិ ដើម្បីអនុវត្តនូវកិច្ចការផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ដែលតែងតែបានណែនាំ និងតម្រង់ទិសលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជួយសង្គ្រោះដល់អ្នកញៀនគ្រឿងញៀន ។

សូមថ្លែងអំណរគុណផងដែរ ដល់គ្រប់ក្រសួង-ស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ផ្នែកសាសនា បុគ្គលពាក់ព័ន្ធទាំងអស់ ព្រមទាំងដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ផ្នែកឯកជន សប្បុរសជន ដែលបានចូលរួមចំណែកជាមួយអាជ្ញាធរជាតិ ក្នុងការធ្វើឱ្យបានសម្រេចលទ្ធផលជាផ្លែផ្កាដូចមានចែងក្នុងរបាយការណ៍ខាងលើ និងសូមអំពាវនាវឱ្យបន្តការគាំទ្រដល់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការអនុវត្តកម្មវិធីការងារឱ្យបានសម្រេចជោគជ័យ តាមទិសដៅការងារត្រួតពិនិត្យគ្រឿងញៀនដែលបានដាក់ចេញសម្រាប់ឆ្នាំ២០១៥ នេះ ។

**ឧបនាយករដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

ចម្លងជូន
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
(ដើម្បីជូនជ្រាប)
-ក្រសួងសមាជិក អ.ជ.ប.គ.ញ
-ក្រសួងផែនការ
-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ
-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត
-នាយកដ្ឋានសរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី
(ដើម្បីមុខការ)
-ឯកសារ